ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ　　សាសនា　　ព្រះមហាក្សត្រ

សភាជំនុំក្តីរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៩២

ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៨

សាលដីកា

លេខ : ៣២

ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១. ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២. លោក ខ៉ឹន ស៊ុន ជាចៅក្រម

៣. លោក ទេវៀល មួន ជាចៅក្រម

៤. លោក ស៊ុខ ឌឹម ជាចៅក្រមរបាយការណ៍

៥. លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

លោក សុង ទៀ

តំណាងអយ្យការ

លោក ដួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥២១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខ ឌឹម យ៉ាត អាយុ ៤០ ឆ្នាំ ជាតិខ្មែរ របរកសិ ធ្វើស្រែ មានទីលំនៅភូមិជើងទឹក " ១ " ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ឌឹម " ស " ម្តាយឈ្មោះ ហួញ សៅ " ស " ប្តីឈ្មោះ លី លឹម ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ឌឹម នី អាយុ ១៩ ឆ្នាំ ជាតិខ្មែរ របរកសិ ធ្វើស្រែ មានទីលំនៅភូមិជើងទឹក ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ហែម ម៉ាត់ " ស " ម្តាយឈ្មោះ ឌឹម អួន " ស " នៅរស់ ។

កម្មវត្ថុ : ប្តឹងទាមទារចែកទ្រព្យសម្បត្តិជាពីរស្មើគ្នា

បានឃើញបណ្តឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ លី លឹម " ប្តីរបស់ឌឹម យ៉ាត " ប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៨.៥.៩៦ របស់ឈ្មោះ ឌឹម នី ប្តឹងទាមទារទ្រព្យសម្បត្តិរបស់ជីតាពីឈ្មោះ ឌឹម យ៉ាត ដោយសំអាងហេតុថា ខ្លួនរស់នៅនៅជាមួយជីតាឈ្មោះ ប៉ែព្រង ឌឹម អស់រយៈពេល ១៥ឆ្នាំ ហើយលុះដល់ពេលតាស្លាប់ទៅឈ្មោះ ឌឹម យ៉ាត ដែលត្រូវជាម្តាយមីងមកពីខេត្តកំពង់ចាម មករស់នៅផ្ទះតាកាន់កាប់ទ្រព្យសម្បត្តិទាំងអស់ហេតុនេះ ខ្លួនប្តឹងមកតុលាការ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៥ ចុះថ្ងៃទី ៣១.៣.៩៧ របស់តុលាការខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

១.ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ឌឹម នី ចុះថ្ងៃទី១៨.៥.៩៦ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២.បែងចែកទ្រព្យសម្បត្តិជាពីរភាគ

ក.ត្រូវបានទៅដើមចោទឈ្មោះ ឌឹម នី

-ដីភូមិក្បាលមានប្រវែង ២៥ម បណ្តោយ ៤១ម ទទឹងក្នុងខាងក្រោយប្រវែង ២៣ម មានព្រំប្រទល់ខាងកើតទល់ថ្នល់ ខាងលិចទល់ថ្នាលតាឌឹម ខាងជើងទល់ដីឈ្មោះ អោ ប៉ុល ខាងត្បូងទល់ដីឈ្មោះ ដឿន តា ។

- មេគោ ២ ក្បាល

- ដីប្រាំងភាគកណ្តាល " ដកផ្នែកខាងកើត " មានព្រំប្រទល់ខាងកើតទល់ដីភូមិ ខាងជើងជាប់ទីសំណាបឈ្មោះ ប្រុក អាន ខាងលិចជាប់ទីសំណាបឈ្មោះ រិន ហ៊ាន ខាងត្បូងជាប់ទីសំណាបឈ្មោះ ជា ហ៊ុន ។

- ដីទីសំណាបដែលមានក្បាលដីខាងកើតប្រវែង ១៤ ៥ម ខាងត្បូងមានប្រវែង ១៩ម ខាងលិចមានប្រវែង ៩ម ខាងជើងមានប្រវែង ២០ម មានព្រំប្រទល់ខាងកើតទល់ឈ្មោះ គង់ សួន ខាងត្បូងទល់ដីតា អុន ខាងលិចទល់ដីឈ្មោះ ស្រ៊ុន អ៊ាន ខាងជើងទល់ដីឈ្មោះ-យន់ មោត ។

- ដីស្រែដែលមានទំហំ ៨៤ម គុណ ៣៩ម មានព្រំប្រទល់ខាងកើតទល់ដីវ៉ុន ណាំ ខាងត្បូងទល់ដីឈ្មោះ អ៊ុំ ញ៉ឹប ខាងលិចទល់ដីឈ្មោះ ស៊ុម នាង ខាងជើងទល់ដីឈ្មោះ អ៊ុំ ញ៉ឹប ចំនួនភាគកណ្តាល ។

- ដីស្រែដំបេមានទំហំ ៤២ម គុណ ៣៣ម មានព្រំប្រទល់ខាងកើតទល់ដីឈ្មោះ អ៊ុក ភាង ខាងត្បូងទល់ដីឈ្មោះ ញ៉ាំ ឃួន ខាងលិចទល់ដីឈ្មោះ អ៊ុន ឡុញ ខាងជើងទល់ដីឈ្មោះ ឌិ ពៀប ។

២- ត្រូវបានទៅចុងចម្លើយឈ្មោះ ឌឹម ង៉ាត

-ដីទីលំនៅបមានក្បាលដីប្រវែង ២០ម ទល់ផ្លូវរទេះ ខាងត្បូងមាន-ប្រវែង ៤០ម ទល់និងដីឈ្មោះ មិត្ត ស្រ៊ុម ខាងលិចមានប្រវែង ១២ម ទល់ដីឈ្មោះ ផូ អ៊ាម ។

-ដីស្រែមានទំហំ ៨៤ម គុណ ៣៨ម មានព្រំប្រទល់ខាងកើតទល់ដីឈ្មោះ-វុន ណាំ ខាងត្បូងទល់ដីឈ្មោះ អ៊ុំ ពៀប ខាងលិចទល់ដីឈ្មោះ ស៊ុម នាង ខាងជើងទល់ដីឈ្មោះ អ៊ុំ ពៀប ចំនួនពាក់កណ្ដាល ។

- ដីស្រែរុំដលមានទំហំ ៤៧ម គុណ ៤០ម មានព្រំប្រទល់ខាងកើតទល់ដីឈ្មោះ វ៉ាន់ រិន ខាងត្បូងទល់ដីឈ្មោះ ញ៉ាំ ឃួន ខាងលិចទល់ដីឈ្មោះ អ៊ុក ភាង ខាងជើងទល់ដីឈ្មោះ ឌិ ពៀប ។

- ដីព្រាំងខាងត្បូងប្រវែង ៨៣ម មានព្រំប្រទល់ជាប់ប្រឡាយទឹក ខាងជើងប្រវែង ១៤០ម មានព្រំប្រទល់ជាប់ដីឈ្មោះ អ៊ុក យ៉ង ខាងលិចប្រវែង ៦៣ម មានព្រំ-ប្រទល់ជាប់ឈ្មោះ ស៊ុន អៀន ត្រូវបានដែកខាងលិចចំនួនពាក់កណ្ដាល ។

- កង់ ១ គ្រឿង

- ជ្រូក ១ ក្បាល

- ផ្ទះ ៣ ខ្នង ទំហំ ១០ម គុណ ៥ ៥០ម ដំបូលប្រក់ក្បឿង គ្រឿងឈើ ជញ្ជាំងក្ដា ៣ ជ្រុង ទនាបឬស្សី ។

ទ្រព្យសម្បត្តិទាំងអស់ស្ថិតនៅភូមិជើងទឹក "ខ" ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង គិតចាប់ពីសាលក្រមចូលជាស្ថាពរ ។

៣. បង្គាប់អោយឈ្មោះ ឌឹម ង៉ាត រុះរើផ្ទះចេញពីដីភូមិក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីសាលក្រមចូលជាស្ថាពរ ។

៤. បង្គាប់អោយឈ្មោះ ឌឹម ង៉ាត ចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី ពន្ធហ៊ឹង ពន្ធចុះបញ្ជីក្ដី ១.៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុកមុនហើយ កាលបើផុតកំណត់ឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយបង់ពន្ធសមាមាត្រ

៤.០០០.០០០រ គុណ ១ / ១០០ = ៤០.០០០រៀល ប្រាក់នេះដាក់ចូលថវិការដ្ឋ ៤០.០០០រ គុណ ៨០ម / ១០០ = ៣២.០០០រៀល បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ៤០.០០០រ គុណ ២០ / ១០០ = ៨.០០០រៀល។

៥. សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត និង សេចក្ដីសំរេចនេះ មានសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល ២ ខែ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ១៦.០៥.៩៧ របស់ឈ្មោះ - អ៊ឹម យ៉ាត ប្ដឹងមិនសុខចិត្ត និងសាលក្រមទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ០៦.៤.៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១២.០៥.៩៧ របស់ឈ្មោះ អ៊ឹម យ៉ាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

២.តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៤៥ ចុះថ្ងៃទី ៣១.៣.៩៧ របស់ - តុលាការខេត្តព្រៃវែង ទុកជាបានការ ។

៣.សំរេចកាត់យកប្រាក់ប្រដាប់ក្ដីនៅថ្នាក់សាលាឧទ្ធរណ៍ គឺ ពន្ធចុះបញ្ជីក្ដី និងពន្ធថ្លឹង ចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់តែមប្រាក់ចំនួន ៤៥០រៀល ចំណាយលើកិច្ច - ប្រកល់ដីកាកោះចំនួន ៥.០០០រៀល និងចំណាយលើអាផ្ទាធរតុលាការចំនួន ៥.០០០រៀល សរុប - ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួចហើយ ។

៤.សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ លី លឹម ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពារចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ លី លឹម ជាម្ចាស់បណ្ដឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ អ៊ឹម នី ជាចុងបណ្ដឹងសាទុក្ខ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

សាលដីការដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ០៦.៤.៩៨ របស់សាលា - ឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់ តទៅ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ អ៊ឹម យ៉ាត ជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា ខ្លួនមិនយល់ស្របនឹងតុលាការខេត្តព្រៃវែងសំរេចទេ ពីព្រោះដីនេះ ឪពុកខ្លួនចែកអោយខ្លួនហើយ ហើយ អ៊ឹម នី ឪពុករបស់ខ្ញុំយកមកចិញ្ចឹមតាំងពីតូច ។ ដីនោះតែ នីផ្ទះដីភូមិទេ ផ្ទះពីដំបូងគាត់ធ្វើជាមួយឈ្មោះ ផល យ៉ុក ពេល ផល យ៉ុក ចុះចេញខ្លួនចេញព្រៃ ២ ពាំងជំនួសអោយផល យ៉ុក ។ ផ្ទះនេះពេលធ្វើមានឈ្មោះខ្លួនដែរ តែស្រប្រាំងខ្លួនមិនថាអ្វីទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ទឹម នី ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា ល្វែង ២ កំពឹងនេះ ខ្លួនមិនដឹងហា ហើយ តាទេយកមកអោយម្តាយមីង ខ្លួន ២ កំពឹង ដីភូមិខ្លួននៅជាមួយតាតាំងពីតូចមិនដែលឃើញម្តាយមីងនៅជាមួយតាខ្លួនទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ២៦.៥.៨៨ របស់លោក លី លឹម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ទាយាទរបស់សពលោក ថៃព្រង ទឹម មានចំនួន ៧ នាក់ ក្នុងចំនួននេះ ៦ នាក់ បានឯកភាពប្រគល់មរតកនេះអោយនាង ទឹម នី ហើយ ដូច្នេះការដែល តុលាការថ្នាក់ក្រោម ធ្វើការបែងចែកទ្រព្យសម្បត្តិមរតកនេះ មានលក្ខណៈត្រឹមត្រូវតាមសមធម៌ហើយ ។ ម្យ៉ាងទៀតអ្នកស្រី ទឹម ម៉ាក ក៏ទទួលបានចំណែកច្រើនហើយដែរ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ០៦.៤.៨៨ របស់សាលាឧទ្ធរណ៍ ដែលប្រកាសសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១.ទទួលបណ្តឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ២៦.៥.៨៨ របស់លោកលី លឹម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹង គតិច្បាប់ ។

២.តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៣៨ ចុះថ្ងៃទី ០៦.៤.៨៨ របស់សាលា.ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣.ទឹកប្រាក់ប្រដាប់ក្តី ដែលអ្នកស្រី ទឹម នី បានបង់ជួសរួចហើយចំនួន - ១៥.០០០ រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ុងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៨.០០០ រៀល ។ តម្រូវអោយអ្នកស្រី ឌឹម យ៉ាត សងប្រាក់ ១៨.០០០រៀល ទៅអ្នកស្រី ឌឹម នីរីញា ។

បង្គាប់អោយអ្នកស្រី ឌឹម យ៉ាត បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តព្រៃវែង ។

ង.សាលដីកានេះ ប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។